# ឥទ្ធិពលផលប៉ះពាល់នៃថង់ប្លាស្ទិក





ជាទូទៅថង់ប្លាស្ទិច ទទួលបាននូវការពេញនិយមសំរាប់ការប្រើប្រាស់ចំពោះអ្នកលក់រាយ និងរួមជាមួយអតិថិជនផងដែរ ដោយសារវាមានតម្លៃថោកជាប់ មានទំងន់ស្រាល ប្រើបានច្រើនយ៉ាងធ្វើឲ្យមានអនាម័យនៅពេលកំពុងប្រើ និងមានការងាយស្រួលក្នុងការយួរចំណីអាហារ និងដាក់ទំនិញផ្សេងៗ ។ ហេតុដូចនេះហើយ បានជាការប្រើប្រាស់ថង់ប្លាស្ទិកមើលទៅហាក់ដូចជាទំនើបជាងប្រើរបស់ផ្សេងទៀត ។ ប៉ុន្តែផ្ទុយទៅវិញការប្រើប្រាស់ថង់ប្លាស្ទិកទាំងនោះបណ្តាលឲ្យមានបញ្ហាជាច្រើន ដូចជាការបំពុល បរិយាកាសសម្លាប់សត្វព្រៃ និងការប្រើប្រាស់ធនធានទាំងឡាយពីដែនដី ។

**១.ថង់ប្លាស្ទិកដែលពង្រាយនៅលើដី:** នៅពេលដែលគេប្រើប្រាស់ថង់ប្លាស្ទិកកាន់តែច្រើនកាកសំណល់នោះត្រូវបានចោលទៅលើទីវាល ឬតែមទានាហើយពីមួយឆ្នាំទៅមួយឆ្នាំថង់ប្លាស្ទិកកាន់តែច្រើនឡើងៗ ហើយវាបានពង្រាយនៅបរិស្ថានជុំវិញ ។ នៅគ្រាមួយនោះវាបានក្លាយជាសំរាម ហើយថង់ប្លាស្ទិកបានហូរចូលនៅតាមផ្លូវទឹក ចំណតនានា មាត់សមុទ្រ និងនៅតាមផ្លូវសាធារណៈនានា ហើយប្រសិនបើសំរាមទាំងនេះត្រូវបានដុតវិញ វាបានចូលលាយឡំជាមួយ ខ្យល់ដែលធ្វើឲ្យមានជាតិពុល និងមានបរិយាកាសអាប់អួរ ។

**២.ថង់ប្លាស្ទិកសម្លាប់សត្វ:** មានសត្វជាច្រើនប្រហែលចំនួន ១០០០០០ ដូចជា ត្រីដូហ្វិន អណ្តើកត្រីបាឡែន ផេនឃ្វិន (penguins) ត្រូវបានសម្លាប់ជារៀងរាល់ឆ្នាំដោយសារថង់ប្លាស្ទិក ។ មានសត្វជាច្រើនបានច្រឡំស៊ីថង់ប្លាស្ទិក ថាជាចំណីបន្ទាប់មកក៏ត្រូវស្លាប់ ។ ហើយអ្វីដែលអាក្រក់ ជាងនេះទៅទៀតនោះគឺសត្វដែលស៊ីថង់ប្លាស្ទិក នោះនៅតែមិនមានបញ្ហា តែក្រោយមកបានងាប់ និងបំបែកជាសត្វតូចៗផ្សេងពីនេះ ។

**៣.ថង់ប្លាស្ទិកជាធាតុដែលមិនអាចបំបែកធាតុដោយខ្លួនឯងបាន :** មួយទៀតដែលជាផលអាក្រក់ចំពោះបរិស្ថាន ដែលបណ្តាលមកពីថង់ប្លាស្ទិកនោះ គឺវាមិនអាចធ្វើការបំបែក ធាតុដោយខ្លួនឯងបាន ។ រយៈពេលនៃការបំបែកធាតុចំពោះថង់ប្លាស្ទិកត្រូវចំណាយពេល ប្រហែល ដល់ទៅ១០០០ឆ្នាំ ។

**៤.ប្រេងឆៅត្រូវបានប្រើប្រាស់សំរាប់ផលិតថង់ប្លាស្ទិក** ៖ បរិមាណប្រេងឆៅគឺវាត្រូវថយចុះ និងមានតម្លៃថ្លៃពីមួយថ្ងៃទៅមួយថ្ងៃ នៅពេលដែលវាត្រូវបានប្រើប្រាស់ពេលបច្ចុប្បន្ន ដើម្បីផលិតថង់ប្លាស្ទិក។ តែទោះជាយ៉ាងណា ប្រសិនបើនៅតែត្រូវការប្រើវាជាចាំបាច់នោះ យើងអាចកាត់បន្ថយបានតាមអ្វីដែលយើងអាចធ្វើបានតាមវិធីតូចៗជាច្រើនដូចជា:

- ការប្រើកន្ត្រកអាចជាជំរើសដ៏ល្អសំរាប់ការឃ្លូរទំនិញនៅតាមហាងទំនិញ
- ការដែលអាចប្រើប្រាស់ថង់ប្លាស្ទិក ដែលប្រើម្តងរួចហើយសាជាថ្មីបាន គឺជាគំនិតដ៏ល្អមួយ ដើម្បីកាត់បន្ថយការទិញថង់ថ្មី។

តែទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលរដ្ឋាភិបាលបានព្យាយាមធ្វើការយ៉ាងច្រើនសំរាប់ការកាត់បន្ថយការប៉ះពាល់នៃថង់ប្លាស្ទិកនៅក្នុងបរិស្ថាន យើងទាំងអស់គ្នាគួរតែមានការទទួលខុសត្រូវ ពីបញ្ហានេះដែរ ព្រោះវាក៏ជាបញ្ហាដែលផ្តល់នូវផលអាក្រក់ដល់យើងទាំងអស់គ្នាដែលកំពុងរស់នៅលើផែនដីនេះផងដែរ ។

**ប្រែសំរួលជាភាសាខ្មែរដោយ ស៊ិន អង្គារសាធ**

**ប្រភព** ៖ www.google.com/ Plastic bags enviroment.